**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# នីតិវិធីប្រតិបត្តិស្តង់ដារ
# ស្តីពី
# ការបង្ការ និងការត្រួតពិនិត្យការចម្លងរោគ ជំងឺកូវីដ-១៩ នៅមូលដ្ឋានសុខាភិបាល និង កន្លែងថែទាំអ្នកជំងឺនៅកម្ពុជា

**ថ្ងៃអង្គារ ១កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤**

**ត្រូវថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២០**

**VERSION 1**

# បញ្ជីមាតិកា


**អារម្ភកថា** ... iii

**សេចក្តីថ្លែងអំណរគុណ** ... iv

**១- សាវតាព័ត៌មាន** ... 1

**២- ការចម្លងជំងឺកូវីដ-១៩** ... 1

**៣- យុទ្ធសាស្រ្តដើម្បីការពារ ឬទប់ស្កាត់ការរីករាលដាលនៃវីរុសបង្កជំងឺកូវីដ-១៩** ... 2

**៤- ការប្រើប្រាស់ឧបករណ៍ការពារខ្លួន** (PPE) ... 2

ក) មូលដ្ឋានសុខាភិបាលៈ មន្ទីរពេទ្យ និងមណ្ឌលសុខភាព ... 3

ខ) មធ្យោបាយធ្វើដំណើរៈ រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ ... 4

គ) នៅសហគមន៍ និងផ្ទះ ... 4

ឃ) នៅមន្ទីរពិសោធន៍ ... 5

**៥- របៀបពាក់ និងដោះឧបករណ៍ការពារខ្លួន** (PPE) ... 6

៥.១- នីតិវិធីសម្រាប់ពាក់ឧបករណ៍ការពារខ្លួន ... 6

៥.២- នីតិវិធីសម្រាប់ដោះឧបករណ៍ការពារខ្លួន ... 6

**៦- ការប្រុងប្រយ័ត្នចំពោះការដាក់នៅដាច់ដោយឡែក** ... 6

**៧- លំហូរអ្នកជំងឺ** ... 7

ក) ការត្រួតពិនិត្យជំងឺដំបូង ... 7

ខ) ការពិគ្រោះជំងឺ ... 8

គ) ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ... 9

**៨- ការគ្រប់គ្រង និងការវាយតម្លៃពីហានិភ័យរបស់បុគ្គលិកថែទាំសុខភាព** ... 9

**៩- ការអនុវត្តន៍ការលាងសម្អាត** ... 10

ក) ការសម្អាតរថយន្តសង្គ្រោះបន្ទាន់ និងយានយន្តបញ្ជូនអ្នកជំងឺ ... 12

ខ) ការសម្អាតកម្រាលគ្រែ ស្រោមខ្នើយ ឯកសណ្ឋានបុគ្គលិក និងសម្លៀកបំពាក់អ្នកជំងឺ ... 12

**១០- ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្រ្ត** ... 13

**ឧបសម្ព័ន្ធ ១. ឧបករណ៍ការពារខ្លួនសម្រាប់ជំងឺកូវីដ-១៩** ... 14

**ឧបសម្ព័ន្ធ២. ការជ្រើសរើស និង បែងចែក ឬ ចរន្តអ្នកជំងឺ** ... 18

## ១- សាវតាព័ត៌មាន

ជំងឺកូវីដ-១៩ ជាជំងឺរលាកផ្លូវដង្ហើមស្រួចស្រាវប្រភេទថ្មីដែលកើតឡើងនៅទីក្រុងវូហានប្រទេសចិន កាលពីខែធ្នូ ឆ្នាំ២០១៩ ហើយបានរីករាលដាលទូទាំងពិភពលោក។ Covid-19 បង្កដោយវីរុស រលាកផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរទី២ (Severe Acute Respiratory Syndrome Coronavirus 2: SARS-CoV-2)។ វីរុសនេះ ខ្លាចពន្លឺកាំរស្មីអ៊ុលត្រាវីយូឡេ កំដៅ និងសារធាតុរម្ងាប់មេរោគដែលផ្ទុកអេតាណុល និងក្លរីន។ ទោះបីជាវីរុសចាប់ផ្ដើមផ្ទុះចេញពីការចម្លងពីសត្វមកមនុស្សក្ដី បច្ចុប្បន្នអ្នកឆ្លងជំងឺនេះ (អ្នកផ្ទុកវីរុស SARS-CoV-2) បានក្លាយជាប្រភពចម្លងជាចម្បង។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ អង្គការសុខភាពពិភពលោក បានប្រកាសថាការផ្ទុះកូវីដ-១៩នេះ គឺជាភាពអាសន្នផ្នែកសុខភាពសាធារណៈដែលជាការព្រួយបារម្ភជាអន្តរជាតិ។ នៅថ្ងៃទី១១ ខែ មីនាឆ្នាំ ២០២០ អង្គការសុខភាពពិភពលោកបានចាត់ទុកការផ្ទុះឡើងនៃជំងឺនេះជាការរាតត្បាតសកល។

ករណីទី១នៃជំងឺកូវីដ-១៩ ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញនៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ របាយការណ៍នៃការរាតត្បាតចុងក្រោយបង្អស់សម្រាប់ប្រទេសកម្ពុជាអាចរកឃើញតាមរយៈ https://covid19-map.cdcmoh.gov.kh/ និង https://covid19-map.cdcmoh.gov.kh/ ។ ក្រសួងសុខាភិបាល ក៏ប្រកាសអំពីបច្ចុប្បន្នភាពនៅលើគេហទំព័រ និងបណ្ដាញសង្គមរបស់ក្រសួង ហើយជាកន្លែងដែលទាញយកសារអប់រំសុខភាពផងដែរ។

## ២- ការចម្លងជំងឺកូវីដ-១៩

- វីរុសដែលបណ្ដាលឱ្យមានជំងឺកូវីដ-១៩ គឺឆ្លងពីមនុស្ស ទៅមនុស្សតាមរយៈដំណក់តូចៗចេញពីផ្លូវដង្ហើមពេលអ្នកជំងឺក្អក ឬកណ្ដាស់ និងការប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។

| | |
|---|---|
| **ដំណក់តូចៗ** | ដំណក់តូចៗតាមផ្លូវដង្ហើម (ភាគល្អិតៗទំហំ >5-10μm) បង្កឡើងនៅពេលដែលអ្នកមានជំងឺមានផ្ទុកវីរុស ក្អក ឬកណ្ដាស់។ បុគ្គលដែលប៉ះពាល់ផ្ទាល់ (នៅចម្ងាយតិចជាង ១ ម៉ែត្រ) ពីអ្នកដែលមានរោគសញ្ញាផ្លូវដង្ហើម (ក្អក កណ្ដាស់) មានហានិភ័យនៃការឆ្លង ដោយសារមាត់ ច្រមុះ ឬភ្នែករបស់អ្នកទាំងនោះបានប៉ះពាល់ទៅនឹងតំណក់ទឹកតូចៗ ដែលផ្ទុកវីរុសផ្លូវដង្ហើមនេះ។ |
| **ការប៉ះពាល់** | ការឆ្លង ក៏អាចកើតឡើងតាមរយៈការប៉ះពាល់អ្នកផ្ទុកកូវីដ-១៩ ផ្ទាល់ និងដោយប្រយោលជាមួយផ្ទៃវត្ថុដែលមានវីរុស (ឧទាហរណ៍ដៃទ្វារ តុធ្វើការ) និងឧបករណ៍ផ្សេងៗទៀត។ |

1. ផ្អែកលើភ័ស្តុតាងបច្ចុប្បន្ន វីរុសដែលបង្កឲ្យមានជំងឺកូវីដ-១៩ មិនឆ្លងតាមខ្យល់ទេ។ ប៉ុន្តែការឆ្លងតាមខ្យល់ (Airborne transmission) អាចកើតមានឡើងនៅពេលអនុវត្តសកម្មភាពទាំងឡាយណាដែល

បង្កើតឲ្យមានសាយភាយភាគល្អិតតូចៗហើរតាមខ្យល់ (Aerosol generation procedures[1])។ ឧទាហរណ៍

- ការឆ្លងតាមខ្យល់សំដៅទៅលើចំណែកភាគល្អិតតូចៗនៅក្នុងខ្យល់ដែលមានអង្កត់ផ្ចិតតូចជាង 5μm ហើយអាចស្ថិតនៅក្នុងខ្យល់បានរយៈពេលយូរ និងអាចឆ្លងក្នុងចម្ងាយឆ្ងាយជាង១ម៉ែត្រ។

## ៣- យុទ្ធសាស្ត្រដើម្បីការពារ ឬទប់ស្កាត់ការរីករាលដាលនៃមេរោគ កូវីដ-១៩

- <u>នៅក្នុងសហគមន៍:</u> វិធានការបង្ការដែលមានប្រសិទ្ធិភាពរួមមាន៖ អនាម័យដៃ ចៀសវាងការប៉ះពាល់លើផ្ទៃមុខរួមមាន ភ្នែក ច្រមុះ និងមាត់ អនាម័យផ្លូវដង្ហើម (ឧទាហរណ៍ ក្អក កណ្តាស់ ខ្ទប់ដោយប្រើកែងដៃ) នៅបន្ទប់ដាច់ដោយឡែកម្នាក់ឯង ប្រសិនបើមិនស្រួលខ្លួន។ ពាក់ម៉ាស់វះកាត់ ប្រសិនបើមានរោគសញ្ញាផ្លូវដង្ហើម និងរក្សាចម្ងាយពីគ្នាអប្បបរមា១ម៉ែត្រ និងទម្លាប់សម្អាតសម្លាប់មេរោគតាមធម្មតា លើផ្ទៃដែលត្រូវប៉ះពាល់ញឹកញាប់។
- <u>នៅក្នុងមូលដ្ឋានសុខាភិបាល:</u> វិធានការបង្ការដែលមានប្រសិទ្ធិភាពរួមមាន៖ ឆាប់កំណត់អត្តសញ្ញាណអ្នកសង្ស័យ និងការត្រួតពិនិត្យប្រភពចម្លងតាមរយៈ ការទទួលនិងបែងចែកជំងឺដំបូង (Triage) និងការត្រួតពិនិត្យរកអ្នកជំងឺដែលសង្ស័យ (Screening)។ អនុវត្តការប្រុងប្រយ័ត្នស្តង់ដារ និង ការប្រុងប្រយ័ត្នបន្ថែមលើការដាក់នៅដាច់ដោយឡែក សម្រាប់ករណីសង្ស័យ និងករណី ជំងឺកូវីដ-១៩ (ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍) ។ ការប្រើប្រាស់ឧបករណ៍ការពារខ្លួន (PPE) សមស្របដោយបុគ្គលិកថៃទាំសុខភាព និងអ្នកជំងឺ។ អនុវត្តការលាងសម្អាត និងការគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវ។ លើសពីនេះ បុគ្គលិកដែលមិនស្រួលខ្លួន ឬមានរោគសញ្ញាផ្លូវដង្ហើមមិនត្រូវមកធ្វើការទេ។

## ៤- ការប្រើប្រាស់ឧបករណ៍ការពារខ្លួន (PPE)

- គោលការណែនាំខាងក្រោម បង្ហាញពី<u>ស្តង់ដារអប្បបរមាសម្រាប់ការពារខ្លួនត្រឹមត្រូវ</u> ដោយផ្អែកលើអនុសាសន៍របស់អង្គការសុខភាពពិភពលោក។
- ត្រូវធ្វើការវាយតម្លៃហានិភ័យជាមុន រួមមានហានិភ័យនៃការប៉ះពាល់ និងទំហំនៃការប៉ះពាល់ឈាម សរីរៈរាវ ដំណក់តូចៗតាមផ្លូវដង្ហើម ឬតាមការរលាត់ស្បែក មុនពេលអនុវត្តសកម្មភាពថៃទាំនីមួយៗ ដើម្បីធានាសុវត្ថិភាពបុគ្គលិក និងបង្កើនប្រសិទ្ធិភាពនៃការប្រើប្រាស់ឧបករណ៍ការពារខ្លួន។
- សម្រាប់សេចក្តីសង្ខេបស្តីពីការប្រើប្រាស់ឧបករណ៍ការពារខ្លួន ត្រឹមត្រូវ អាស្រ័យទៅតាម ទីកន្លែងបុគ្គលិក និងប្រភេទនៃសកម្មភាព សូមមើលឧបសម្ព័ន្ធ ១។

---

[1] Aerosol-generating procedures (AGP), រួមមានទម្រង់ការទាំងឡាយណាដែលបង្កើតឲ្យមានសាយភាយភាគល្អិតតូចៗហើរតាមខ្យល់ endotracheal intubation, airway suction, cardiopulmonary resuscitation, tracheostomy, nebulizer treatment, sputum induction, and bronchoscopy.

## ក) មូលដ្ឋានសុខាភិបាល៖ មន្ទីរពេទ្យ និងមណ្ឌលសុខភាព

| | |
|---|---|
| **បុគ្គលិកថែទាំសុខភាព** | • ការទទួល និងបែងចែកជំងឺដំបូង និងត្រួតពិនិត្យរកអ្នកសង្ស័យ (Screening) បើមិនពាក់ព័ន្ធនឹងការប៉ះពាល់អ្នកជំងឺផ្ទាល់ នោះមិនតម្រូវឱ្យពាក់ឧបករណ៍ការពារខ្លួនឡើយ គ្រាន់តែត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ។ នៅពេលដែលការអនុវត្តនៃការរក្សាគំលាតពីគ្នាមិនអាចធ្វើបាន ត្រូវពាក់ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ។<br>• ការវាយតម្លៃវេជ្ជសាស្ត្រ ការបែងចែកអ្នកជំងឺ ការជ្រើសរើសអ្នកជំងឺលើកទីពីរនៅក្នុងបន្ទប់ពិគ្រោះជំងឺ ជាមួយអ្នកជំងឺដែលមានរោគសញ្ញាផ្លូវដង្ហើម ត្រូវពាក់ ម៉ាស់វះកាត់ ស្រោមដៃ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់ (Gown)។<br>• ការថែទាំដោយផ្ទាល់ទៅលើអ្នកជំងឺដែលសង្ស័យនិង អ្នកជំងឺកូវីដ-១៩ ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់។ សម្រាប់សកម្មភាពទាំងឡាយណា ដែលអាចបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់ (ឧ សកម្មភាពសង្គ្រោះបន្ទាន់មួយចំនួន ដូចជាការប្រើប្រាស់ឧបករណ៍ជំនួយដង្ហើមជាដើម) ត្រូវពាក់បន្ថែម ម៉ាស់ N95 និង អាវអៀមមិនជ្រាបទឹក។<br>• ការប្រមូលសំណាកពីផ្លូវដង្ហើមសម្រាប់មន្ទីរពិសោធន៍ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់។ សម្រាប់ការប្រមូលសំណាកនៃផ្លូវដង្ហើមដោយប្រើនីតិវិធីណាដែលអាចបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់ ត្រូវពាក់បន្ថែមម៉ាស់ N95 និង អាវអៀម។ |
| **បុគ្គលិកអនាម័យ** | • នៅពេលលាងសម្អាតបន្ទប់ពិគ្រោះជំងឺក្រៅ និងបន្ទប់ជំងឺសម្រាកពេទ្យ ត្រូវពាក់ស្រោមដៃក្រាស់ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ អាវបំពង់ ស្បែកជើងកវែង ឬស្បែកជើងបិទជិត។ |
| **បុគ្គលិកផ្សេងទៀត (រដ្ឋបាលសន្តិសុខ)** | • ការងាររដ្ឋបាល និងសន្តិសុខ ដែលមិនពាក់ព័ន្ធនឹងការប៉ះពាល់អ្នកជំងឺផ្ទាល់ មិនតម្រូវឱ្យពាក់ឧបករណ៍ការពារខ្លួនឡើយ តែត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ។ |
| **អ្នកជំងឺ** | • អ្នកជំងឺទាំងអស់ ដែលចូលក្នុងមូលដ្ឋានព្យាបាល និងថែទាំសុខភាពមានរោគសញ្ញាផ្លូវដង្ហើម ត្រូវតែពាក់ម៉ាស់វះកាត់។ |

## ខ) មធ្យោបាយធ្វើដំណើរ៖ រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ

| | |
|---|---|
| **បុគ្គលិកថែទាំសុខភាព** | • ការដឹកអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ទៅមូលដ្ឋានសុខាភិបាល ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់។ |
| **អ្នកបើកបរ** | • ពេលបើកបរបញ្ជូនអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ពីមូលដ្ឋានសុខាភិបាលមួយ ទៅមូលដ្ឋានសុខាភិបាលមួយទៀត មិនតម្រូវឱ្យពាក់ឧបករណ៍ការពារខ្លួនឡើយ បើកន្លែងអ្នកបើកបរខណ្ឌដាច់ពីអ្នកជំងឺ តែត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ។<br>• ត្រូវពាក់ម៉ាស់វះកាត់ បើពេលបើកបរ ហើយបើកន្លែងអ្នកបើកបរ មិនខណ្ឌដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩។<br>• នៅពេលជួយលើកដាក់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ និងអាវបំពង់ |
| **បុគ្គលិកអនាម័យ** | • នៅពេលលាងសម្អាតរថយន្តបញ្ជូនជំងឺ ត្រូវពាក់ស្រោមដៃក្រាស់ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ អាវបំពង់ ស្បែកជើងកវែង ឬស្បែកជើងបិទជិត។ |
| **អ្នកជំងឺ** | • គ្រប់អ្នកជំងឺមានរោគសញ្ញាផ្លូវដង្ហើម ត្រូវតែពាក់ម៉ាស់វះកាត់។ |

## គ) នៅសហគមន៍ និងផ្ទះ

| | |
|---|---|
| **ក្រុមឆ្លើយតបបន្ទាន់** | • ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកជំងឺសង្ស័យ ឬអ្នកជំងឺ កូវីដ-១៩ ត្រូវតែពាក់ម៉ាស់វះកាត់ និងត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច១ ម៉ែត្រ។ ការសម្ភាសន៍ ត្រូវធ្វើនៅខាងក្រៅផ្ទះ។ អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវតែពាក់ម៉ាស់វះកាត់។<br>• ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកប៉ះពាល់អ្នកជំងឺកូវីដ- ១៩ ហើយមិនមានរោគសញ្ញា មិនតម្រូវឱ្យពាក់ឧបករណ៍ការពារខ្លួនឡើយ តែត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ<br>• ការប្រមូលសំណាកពីផ្លូវដង្ហើមសម្រាប់មន្ទីរពិសោធន៍ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬក្បាំងការពារមុខ និងអាវបំពង់។ |
| **បុគ្គលិកថែទាំសុខភាព** | • ការប៉ះពាល់ផ្ទាល់នឹងអ្នកជំងឺសង្ស័យ និងអ្នកជំងឺកូវីដ- ១៩ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬក្បាំងការពារមុខនិងអាវបំពង់។ |

| | |
|---|---|
| អ្នកមើលថែអ្នកជំងឺ | • ការមើលថែអ្នកជំងឺដែលសង្ស័យ និងអ្នកជំងឺបញ្ជាក់ជំងឺកូវីដ-១៩ ឬលាងសម្អាតលាមក ទឹកនោម ឬកាកសំណល់របស់អ្នកជំងឺកូវីដ-១៩ ត្រូវពាក់ស្រោមដៃ ម៉ាស់វះកាត់ វ៉ែនតាការពារភ្នែក ឬក្បាំងការពារមុខ និងអាវអៀម ប្រសិនប្រឈមនឹងការខ្ទាតខ្ទាយ។<br>• ពេលចូលក្នុងបន្ទប់អ្នកជំងឺសង្ស័យ និងអ្នកជំងឺបញ្ជាក់ជំងឺកូវីដ-១៩ ប៉ុន្តែមិនផ្តល់ការថែទាំដោយផ្ទាល់ ត្រូវពាក់ម៉ាស់វះកាត់។ |
| អ្នកជំងឺ | • គ្រប់អ្នកជំងឺមានរោគសញ្ញាផ្លូវដង្ហើមត្រូវតែពាក់ម៉ាស់វះកាត់និងត្រូវអនុវត្តការរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ។ |

## ឃ) នៅមន្ទីរពិសោធន៍

| | |
|---|---|
| **អ្នកបច្ចេកទេសមន្ទីរពិសោធន៍** | • ការធ្វើតេស្តរោគវិនិច្ឆ័យប្រើវិធីសាស្ត្រ ម៉ូលីគុល (រៀបចំធ្វើ RT-PCR) ត្រូវពាក់ស្រោមដៃ គម្របសក់ អាវបំពង់គ្របជិតមានដៃ (Coverall), គម្របស្បែកជើង និងវ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ។ ការវាយតម្លៃហានិភ័យអាចប្រាប់ឲ្យដឹងពីតម្រូវការប្រើសម្ភារៈការពារផ្លូវដង្ហើម (ឧទាហរណ៍ពាក់ម៉ាស់ N95) ។<br>• បុគ្គលិកមន្ទីរពិសោធន៍ត្រូវអនុវត្តតាមនីតិវិធីស្តង់ដារ និងបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវពីជីវសុវត្ថិភាពកម្រិត២ និង ៣ (P2/P3)។<br>• អាចចូលមើលវីដេអូពីរបៀបនៃការប្រើប្រាស់ឧបករណ៍ការពារខ្លួនក្នុងមន្ទីរពិសោធន៍សុវត្ថិភាពជីវសាស្ត្រកម្រិត២ https://bit.ly/2OqA5Be និង ៣ https://bit.ly/3h9H91D របស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ |

### គំណត់ចំណាំបន្ថែម

- ប្រសិនបើអាវបំពង់មិនធន់នឹងការជ្រាបទឹក ហើយមានហានិភ័យ ដែលប្រឈមនឹងការប៉ះពាល់សរីរៈរាវ ក្នុងកំឡុងពេលធ្វើទម្រង់ការ នោះត្រូវពាក់អាវអៀមមិនជ្រាបទឹកដែរ។ នេះត្រូវតែផ្អែកលើការវាយតម្លៃហានិភ័យ។
- មិនត្រូវពាក់គម្របសក់ អាវបំពង់គ្របជិត (Coverall) ស្បែកជើងកៅស៊ូកវែង នៅពេលផ្តល់ការថែទាំដោយផ្ទាល់ដល់អ្នកជំងឺដែលសង្ស័យនិងបញ្ជាក់ជំងឺកូវីដ-១៩ទេ។
- មិនត្រូវប្រើប្រាស់ស្រោមដៃតែ១គូចំពោះអ្នកជំងឺកូវីដ-១៩ ពីអ្នកជំងឺម្នាក់ទៅម្នាក់ទៀតទេ។ ត្រូវធ្វើអនាម័យដៃរាល់ពេលដូរស្រោមដៃម្តងៗ។
- ការប្រើស្រោមដៃពីរជាន់មិនផ្តល់អនុសាសន៍ឡើយ លើកលែងតែពិធីសារវះកាត់ដែលប្រឈមខ្លាំងក្នុងការបែកធ្លាយ។

## ៥- របៀបពាក់ និងដោះឧបករណ៍ការពារខ្លួន ( PPE )

### ៥១.- នីតិវិធីសម្រាប់ពាក់ឧបករណ៍ការពារខ្លួន

1. ធ្វើការវាយតម្លៃហានិភ័យជាមុន រួមមានការប៉ះពាល់ និងទំហំនៃការប៉ះពាល់ឈាម សរីរៈរាវ ដំណក់តូចៗតាមផ្លូវដង្ហើម ឬតាមការរលាត់ស្បែក មុនពេលអនុវត្តសកម្មភាពថៃទាំនីមួយៗ។ ជ្រើសរើសឧបករណ៍ការពារខ្លួន ផ្អែកលើលទ្ធផលនៃការវាយតំលៃនេះ។
2. លាងដៃរបស់អ្នកជាមួយសាប៊ូ និងទឹក (៤០-៦០ វិនាទី) ឬអាល់កុល (២០-៣០ វិនាទី) មុនពេលពាក់ឧបករណ៍ការពារខ្លួន។
3. ពាក់អាវបំពង់
4. ពាក់ម៉ាស់វះកាត់ ការប្រុងប្រយ័ត្នចំពោះមេរោគឆ្លងតាមរយៈការប៉ះពាល់នឹងដំណត់តូចៗ។ ពាក់ម៉ាស់ N95 សម្រាប់សកម្មភាពទាំងឡាយណាដែលបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់។
5. ពាក់វ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ។
6. ពាក់ស្រោមដៃ ត្រូវធានាថាស្រោមដៃត្រូវបានពាក់ស្រោបពីលើដៃអាវបំពង់។

### ៥.២- នីតិវិធីសម្រាប់ដោះឧបករណ៍ការពារខ្លួន

1. ដោះស្រោមដៃ និងធ្វើអនាម័យដៃ
2. ដោះអាវបំពង់ ត្រូវធានាដោះចេញដោយប្រុងប្រយ័ត្នកុំឲ្យខ្ទាតរបស់ផ្សេងទៀតចេញពីអាវបំពង់ និងធ្វើអនាម័យដៃ
3. ដោះវ៉ែនតាការពារភ្នែក ឬក្បាំងការពារមុខ និងធ្វើអនាម័យដៃ
4. ដោះម៉ាស់
5. លាងដៃរបស់អ្នកជាមួយសាប៊ូនិងទឹក (៤០-៦០ វិនាទី) ឬអាល់កុល (២០-៣០ វិនាទី) ម្តងទៀត។

❖ **កំណត់ចំណាំបន្ថែម**

- ពាក់ឧបករណ៍ការពារខ្លួន ដែលល្មមត្រូវនឹងខ្លួន ដើម្បីធានាថាម៉ាស់ និងវ៉ែនតារបស់អ្នកមិនរអិល
- ហាមប៉ះមុខរបស់អ្នក ក្នុងពេលពាក់ឧបករណ៍ការពារខ្លួន
- មិនត្រូវពាក់ម៉ាស់ ប្រសិនបើវាខូច មានសំណើម ឬអ្នកបានប៉ះវាដោយដៃមិនស្អាត
- មិនត្រូវប្រើឡើងវិញនូវឧបករណ៍ការពារខ្លួន ដែលបានបោះចោលហើយ
- លាងសម្អាត និងរម្ងាប់មេរោគឧបករណ៍ការពារខ្លួនណា ដែលអាចប្រើឡើងវិញបាន
- មិនមានភ័ស្តុតាង ដែលអាចទុកចិត្តបានស្តីពីការបាញ់សារធាតុសម្លាប់មេរោគ នៅឧបករណ៍ការពារខ្លួន បន្ទាប់ពីប្រើប្រាស់រួចនោះឡើយ

## ៦- ការប្រុងប្រយ័ត្នចំពោះការដាក់នៅដាច់ដោយឡែក

- ការប្រុងប្រយ័ត្ន ត្រូវបានណែនាំដូចខាងក្រោម៖

| | |
|---|---|
| **ករណីសង្ស័យ / បញ្ជាក់ជំងឺកូវីដ-១៩** | ប្រុងប្រយ័ត្នជាស្តង់ដារ + ប៉ះពាល់ + ដំណក់តូចៗ (Standard + Contact + Droplet ) |
| **ករណីសង្ស័យ / បញ្ជាក់ជំងឺកូវីដ-១៩ អំឡុងពេលធ្វើ aerosol generating procedure**[1] | ប្រុងប្រយ័ត្នជាស្តង់ដារ + ប៉ះពាល់ + ឆ្លងតាមខ្យល់+ ការពារភ្នែក (Standard + Contact + Airborne) + eye protection |

- ករណីសង្ស័យ ឬ អ្នកជំងឺកូវីដ-១៩ ត្រូវតែដាក់នៅក្នុងបន្ទប់ដាច់ដោយឡែកដែលមានខ្យល់ចេញចូលគ្រប់គ្រាន់ ប្រសិនបើអាច។
- នៅពេលដែលមិនមានបន្ទប់ដាច់ដោយឡែក សម្រាប់ម្នាក់ៗ អ្នកជំងឺកូវីដ-១៩ អាចត្រូវដាក់ក្នុងបន្ទប់រួមគ្នា។
- កុំដាក់ករណីសង្ស័យជំងឺកូវីដ-១៩ និង ករណីជំងឺកូវីដ-១៩ (ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍) ក្នុងបន្ទប់រួមគ្នា។
- រៀបចំដាក់គ្រែឲ្យមានគំលាតយ៉ាងតិច ១ម៉ែត្រពីគ្នា។
- ក្នុងករណីដែលអាចធ្វើទៅបាន សូមចាត់តាំងបុគ្គលិកថែទាំបំរុងសម្រាប់តែអ្នកដែលមានជំងឺកូវីដ ១៩ ប៉ុណ្ណោះ ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ។
- ប្រើឧបករណ៍ ដែលអាចប្រើម្តងហើយចោល ឬឧបករណ៍ ដែលបានបម្រុងសម្រាប់តែជំងឺកូវីដ-១៩ (ឧទាហរណ៍ ប្រដាប់ស្ទង់កំដៅ ប្រដាប់វាស់សម្ពាធឈាម ស្តេតូស្កុប)។
- ប្រសិនបើបរិក្ខារចាំបាច់ណាត្រូវប្រើប្រាស់ ពីអ្នកជំងឺម្នាក់ទៅម្នាក់ទៀត ត្រូវលាងសម្អាត និងរម្ងាប់មេរោគជាមួយអេទីលអាល់កុល៧០%សិនមុននឹងប្រើសម្រាប់អ្នកជំងឺបន្ទាប់។
- ប្រើឧបករណ៍កាំរស្មីអ៊ិចចល័ត និងឧបករណ៍ធ្វើរោគវិនិច្ឆ័យសំខាន់ៗផ្សេងទៀត ដែលបម្រុងសម្រាប់តែអ្នកជំងឺកូវីដ ១៩ ។ ប្រសិនបើចាំបាច់តម្រូវឲ្យបញ្ជូនអ្នកជំងឺ ត្រូវប្រើផ្លូវបញ្ជូនដែលបានកំណត់ជាមុន ហើយឱ្យអ្នកជំងឺពាក់ម៉ាស់វះកាត់។
- សកម្មភាពទាំងឡាយណា ដែលបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់ (Aerosol generating procedures) ត្រូវធ្វើនៅក្នុងបន្ទប់ដែលមានខ្យល់ចេញចូលគ្រប់គ្រាន់ ប្រើខ្យល់ចេញចូលតាមធម្មជាតិដែលមានលំហូរខ្យល់យ៉ាងតិច ១៥០លីត្រក្នុង១ វិនាទី សម្រាប់មនុស្សម្នាក់។ ចំនួនមនុស្សនៅក្នុងបន្ទប់ ត្រូវតែកំណត់ត្រឹមចំនួនអប្បបរមា ដែលចាំបាច់សម្រាប់ការថែទាំព្យាបាល។

## ៧- លំហូរអ្នកជំងឺ

សូមមើលឧបសម្ព័ន្ធទី២ សម្រាប់គំនូរបំព្រួញនៃការជ្រើសរើស បែងចែក និងលំហូរអ្នកជំងឺជំងឺកូវីដ-១៩

### ក) ការត្រួតពិនិត្យជំងឺដំបូង

- ការត្រួតពិនិត្យជំងឺដំបូងដើម្បីរកអ្នកសង្ស័យត្រូវធ្វើឡើងនៅច្រកចូលនៃមូលដ្ឋានសុខាភិបាល និងងត្រូវធ្វើឡើងដោយឡែកពីផ្នែកពិនិត្យជំងឺក្រៅ

- គោលបំណងនៃការត្រួតពិនិត្យជំងឺដំបូងគឺដើម្បីការពារករណីកូវីដ-១៩ ដែលអាចកើតឡើង កុំឲ្យឆ្លងទៅកន្លែងផ្តល់សេវាធម្មតាផ្សេងទៀត ដូចជា ផ្នែកពិនិត្យជំងឺក្រៅ ផ្នែកសម្ភព និងផ្នែកវះកាត់ ។ល។
- គ្រប់បុគ្គលដែលចូលទៅក្នុងមូលដ្ឋានសុខាភិបាល ត្រូវបានជ្រើសរើសតាមរយៈការវាស់កម្តៅ ដោយប្រើឧបករណ៍ស្ទង់កម្តៅដែលមិនប៉ះផ្ទាល់ (Infrared Thermometer) រួចសួរសំណួរដូចខាងក្រោម៖
    - ក្តៅខ្លួនយ៉ាងតិច ៣៧.៥ អង្សាសេ ឬ
    - ក្អក ឬ
    - ហៀរសំបោរ ឬ
    - ឈឺបំពង់ក ឬ
    - ពិបាកដកដង្ហើម
    - អ្នកគ្មានរោគសញ្ញា តែបានប៉ះពាល់អ្នកជំងឺកូវីដ-១៩

(យោងតាមនិយមន័យករណីសង្ស័យជំងឺកូវីដ-១៩របស់ក្រសួងសុខាភិបាលចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០)

- ប្រសិនបើមានរោគសញ្ញាខាងលើណាមួយ បុគ្គលនោះនឹងត្រូវចាត់ទុកជា អ្នកសង្ស័យជំងឺកូវីដ-១៩ និងត្រូវបានផ្តល់ជូនម៉ាស់វះកាត់ រួចបញ្ជូនទៅកាន់កន្លែងរង់ចាំសម្រាប់អ្នកសង្ស័យជំងឺកូវីដ-១៩ ដើម្បីវាយតម្លៃបន្ថែមដោយក្រុមអ្នកជំនាញ។ ត្រូវរក្សាគម្លាតយ៉ាងតិច ១ម៉ែត្រពីអ្នកជំងឺសង្ស័យ។
- ប្រសិនបើពុំមានរោគសញ្ញាណាមួយខាងលើទេ បុគ្គលនោះអាចចូលទៅកាន់ផ្នែកពិនិត្យជំងឺក្រៅ ឬផ្នែកសម្រាកពេទ្យ។

## ខ) ការពិគ្រោះជំងឺ

- ជំហាននៃការពិគ្រោះជំងឺ រួមមាន៖ ការទទួលនិងបែងចែកជំងឺដោយមានការវាយតម្លៃច្បាស់លាស់ (Acuity-based triage) និង ការត្រួតពិនិត្យជំងឺដើម្បីស្វែងរកអ្នកសង្ស័យលើកទី២ (Second screening)

| | |
|---|---|
| ការទទួលនិងបែងចែកជំងឺដោយមានការវាយតម្លៃច្បាស់លាស់ | • គឺជាវិធីសាស្រ្តស្តង់ដារសម្រាប់បែងចែកអ្នកជំងឺនៅក្នុងមូលដ្ឋានសុខាភិបាល<br>• ត្រូវបានប្រើប្រាស់សម្រាប់កំណត់ អ្នកជំងឺដែលត្រូវការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្រ្តភ្លាម និងអ្នកជំងឺដែលអាចរង់ចាំបានដោយមានសុវត្ថិភាព ឬអ្នកជំងឺដែលអាចបញ្ជូនទៅមូលដ្ឋានសុខាភិបាលដែលមានសមត្ថភាពខ្ពស់ជាង ដោយយោងទៅតាមស្ថានភាពជំងឺរបស់គាត់។<br>• អ្នកជំងឺដែលមានរោគសញ្ញាធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅផ្នែកថែទាំជំងឺធ្ងន់ធ្ងរជាបន្ទាន់ និងយកសំណាកផ្លូវដង្ហើមធ្វើតេស្តនៅមន្ទីរពិសោធន៍ និងចាត់ទុកជាជំងឺសង្ស័យ រហូតដល់មានការបញ្ជាក់លទ្ធផលពីមន្ទីរពិសោធន៍។ |

| | |
|---|---|
| ការត្រួតពិនិត្យជំងឺដើម្បីស្វែងរកអ្នកសង្ស័យលើកទី២ | • សម្រាប់អ្នកជំងឺ ដែលមានរោគសញ្ញាស្រាល ឬមធ្យម ការត្រួតពិនិត្យជំងឺដើម្បីស្វែងរកអ្នកសង្ស័យលើកទី២ ត្រូវធ្វើឡើងដោយសួរសំណួរដូចខាងក្រោម៖<br>- ការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ឬក្រៅប្រទេសកម្ពុជាក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ<br>- ការប៉ះពាល់នឹងនរណាម្នាក់ ដែលបានធ្វើដំណើរទៅក្រៅប្រទេសកម្ពុជារយៈពេល ១៤ ថ្ងៃចុងក្រោយ<br>- ការប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍ ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ<br>- បុគ្គលិកសុខាភិបាល<br>• ប្រសិនបើមានរោគសញ្ញាណាមួយខាងលើ ត្រូវប្រមូលសំណាកសម្រាប់មន្ទីរពិសោធន៍ ហើយត្រូវដាក់អ្នកជំងឺឲ្យនៅដាច់ដោយឡែកនៅកន្លែងដែលបានកំណត់កំឡុងពេលរង់ចាំលទ្ធផល។<br>• ប្រសិនបើគ្មានរោគសញ្ញាណាមួយខាងលើទេ អ្នកជំងឺអាចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះ ដើម្បីដាក់ខ្លួនឲ្យនៅដាច់ដោយឡែក។ ទាំងនេះ ត្រូវផ្អែកទៅលើការវាយតម្លៃវេជ្ជសាស្ត្រ ។ |

### គ) ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ

- ប្រសិនបើ**អ្នកជំងឺមានតេស្តវិជ្ជមាន** គាត់ត្រូវបានចាត់ទុកថាជាករណីជំងឺកូវីដ-១៩ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍ ហើយត្រូវបានដាក់ឲ្យសម្រាករួមគ្នាក្នុងបន្ទប់ជាមួយអ្នកជំងឺកូវីដ-១៩ដែលមានការបញ្ជាក់ពីមន្ទីរពិសោធន៍ផ្សេងទៀត។ ត្រូវផ្តល់ព័ត៌មានជូនទៅនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងរបស់ក្រសួងសុខាភិបាលជាបន្ទាន់។
- ប្រសិនបើអ្នកជំងឺមានតេស្តអវិជ្ជមាន គាត់ត្រូវបានចាត់ថាជាករណី**មិនមែន**ជំងឺកូវីដ-១៩ ហើយអាចត្រឡប់ទៅផ្ទះ ដើម្បីដាក់ខ្លួនឯងឲ្យនៅដាច់ដោយឡែក ជាមួយនិងការជួយគាំទ្រដោយផ្តល់ឯកសារអប់រំសុខភាព។

## ៨- ការគ្រប់គ្រង និងការវាយតម្លៃពីហានិភ័យរបស់បុគ្គលិកថែទាំសុខភាព

- បុគ្គលិកថែទាំសុខភាពដែលផ្តល់ការថែទាំដោយផ្ទាល់ដល់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ ត្រូវតាមដានអាការៈរោគសញ្ញាដោយខ្លួនឯង (ឧទាហរណ៍ គ្រុនក្តៅ ក្អក ហៀរសំបោរ ដង្ហើមខ្លី) និងធ្វើការវាយតម្លៃពីហានិភ័យ ប្រសិនបើគាត់មានទាក់ទងនិងការប្រឈមនឹងវីរុស។
- មូលដ្ឋានសុខាភិបាលអាចប្រើឧបករណ៍វាយតម្លៃពីហានិភ័យទាក់ទងនឹងជំងឺកូវីដ-១៩របស់អង្គការសុខភាពពិភពលោក សម្រាប់បុគ្គលិកថែទាំសុខភាព ដើម្បីវាយតម្លៃកម្រិតហានិភ័យ។

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវបានចាត់ទុកថាមានការប្រឈមហានិភ័យខ្ពស់៖

| សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ | សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ |
|---|---|
| • បញ្ឈប់រាល់សកម្មភាពទាក់ទងជាមួយអ្នកជំងឺក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩<br>• ធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្នុងកន្លែងដែលបានរៀបចំទុក<br>• ត្រូវធ្វើតេស្តវីរុសកូវីដ-១៩ | • ផ្តល់ការបណ្តុះបណ្តាលឡើងវិញពីការបង្ការ និងទប់ស្កាត់ការចម្លងរោគសម្រាប់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាល រួមមានស្តង់ដា និងការប្រុងប្រយ័ត្នដាក់ដាច់ដោយឡែក និងការប្រើប្រាស់ឧបករណ៍ការពារខ្លួនឲ្យបានត្រឹមត្រូវ។<br>• ផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមដល់បុគ្គលិកសុខាភិបាល ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក ឬ អំឡុងពេលឈឺ ប្រសិនបើគាត់ក្លាយជាអ្នកជំងឺកូវីដ-១៩។<br>• ផ្តល់ការទូទាត់ជូនបុគ្គលិកសុខាភិបាលសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬ ឈឺ (ប្រសិនបើមិនមានក្នុងប្រាក់បៀវត្សប្រចាំខែ) ឬបន្តកិច្ចសន្យាសម្រាប់រយៈពេលធ្វើចត្តាឡីស័ក ឬមានជំងឺ។ |

ប្រសិនបើបុគ្គលិកថែទាំសុខភាពត្រូវបានចាត់ទុកថាមានហានិភ័យទាប៖

| សកម្មភាពដែលបុគ្គលិកសុខាភិបាលត្រូវធ្វើ | សកម្មភាពដែលមូលដ្ឋានសុខាភិបាលត្រូវធ្វើ |
|---|---|
| • កត់ត្រាសម្រាប់ ១៤ ថ្ងៃ ពីថ្ងៃបានប៉ះពាល់ចុងក្រោយជាមួយអ្នកជំងឺកូវីដ-១៩: សីតុណ្ហភាពរបស់អ្នក និងប្រសិនបើអ្នកមានក្អក ហៀរសំបោរ ឬដកដង្ហើមហត់<br>• ទាក់ទងទៅមូលដ្ឋានសុខាភិបាល ប្រសិនបើអ្នកមានកើតនូវរោគសញ្ញា ដែលអាចសន្និតថាជាជំងឺកូវីដ-១៩ | • ពង្រឹងការប្រុងប្រយ័ត្នស្តង់ដា និងការប្រុងប្រយ័ត្នលើការដាក់ដាច់ដោយឡែក និងការប្រើឧបករណ៍ការពារខ្លួនត្រឹមត្រូវ ដល់បុគ្គលិកក្នុងមូលដ្ឋានសុខាភិបាលទាំងអស់ |

## ៩- ការអនុវត្តន៍ការលាងសម្អាត

- លាងសម្អាតសម្ភារៈដោយប្រើសាប៊ូ និងទឹក គ្រាន់តែជាការជម្រះសារធាតុផ្សេងៗ (ឧទាហរណ៍ ធូលីដី ឈាម ទឹកមាត់ ទឹករំអិល សំបោ ទឹកភ្នែក។ ល។ ) ប៉ុន្តែវាមិនមែនជាការសម្លាប់វីរុសដែលបង្កជំងឺកូវីដ-១៩ ទេ។
- ការប្រើសារធាតុរម្ងាប់មេរោគគឺជាការចាំបាច់ ដើម្បីកម្ចាត់វីរុសដែលបង្កអោយមានជំងឺកូវីដ-១៩។

- សារធាតុរម្ងាប់មេរោគដែលមានប្រសិទ្ធិភាពប្រឆាំងនឹងជំងឺកូវីដ-១៩ រួមមាន៖

| | |
|---|---|
| 70% ethyl alcohol | ដើម្បីរម្ងាប់មេរោគនៅកន្លែងឬរបស់តូចៗមុននិងក្រោយប្រើប្រាស់ដូចជាសម្ភារៈដែលអាចប្រើឡើងវិញបាន (ឧទាហរណ៍ ទែម៉ូម៉ែត្រ ស្តេតូស្កុប) |
| Sodium hypochlorite (bleach) at 0.5% | ដើម្បីរម្ងាប់មេរោគលើតំបន់ដែលមានប្រឡាក់ឈាម និងសារធាតុរាវ |
| Sodium hypochlorite at 0.1% | ដើម្បីរម្ងាប់មេរោគលើផ្ទៃនិងឧបករណ៍វេជ្ជសាស្ត្រ |
| Chlorine at 0.5% | ដើម្បីរម្ងាប់មេរោគលើផ្ទៃការូ |
| Chlorine at 0.05% | ដើម្បីរម្ងាប់មេរោគលើវ៉ែនតា របាំងការពារមុខ ឬវ៉ែនតាសុវត្ថិភាព (*សម្អាតមុនជាមួយសាប៊ូនិងទឹក បន្ទាប់មកត្រាំក្នុង ក្លរីនក្នុងអត្រា ០.០៥%) |

- ត្រូវពាក់ របាំងមុខ វ៉ែនតា អាវបំពង់ និងស្រោមដៃកវែងក្រាស់ នៅពេលលាយក្លរីន ព្រោះក្លរីនអាចបណ្តាលឱ្យរលាកប្រព័ន្ធដង្ហើម និងស្បែក។
- ត្រូវសម្អាតបន្ទប់ យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ។ ត្រូវតែធ្វើការសម្អាតចុងក្រោយ នៅពេលដែលអ្នកជំងឺចេញពីមន្ទីរពេទ្យ។
- សម្អាតញឹកញាប់កន្លែង ដែលប៉ះពាល់ច្រើន ដូចជា ដៃទ្វារ និងកៅអីបង់
- គោលការណ៍គ្រឹះនៃការលាងសម្អាត និងរម្ងាប់មេរោគត្រូវអនុវត្តទៅគ្រប់ផ្នែកថែទាំអ្នកជំងឺ។
- ត្រូវប្រាកដជានិច្ចថា បានសម្អាតឧបករណ៍ថែទាំអ្នកជំងឺ នៅក្រោយពេលប្រើប្រាស់ម្តងៗ។
- សូមផ្គត់ផ្គង់សម្ភារៈសម្អាតអោយបានគ្រាប់គ្រាន់ នៅក្នុងកន្លែងដែលមានហានិភ័យខ្ពស់ (ឧទាហរណ៍ នៅក្នុងបន្ទប់ដាច់ដោយឡែក បន្ទប់សម្រាល និងបន្ទប់វះកាត់)។
- ការផ្គត់ផ្គង់សម្ភារសម្អាតសម្រាប់បន្ទប់ដាច់ដោយឡែក ត្រូវរក្សាទុកសម្រាប់ប្រើប្រាស់តែនៅក្នុងបន្ទប់នោះ។
- ត្រូវសម្អាតពីតំបន់ស្អាតបំផុតទៅតំបន់ដែលកខ្វក់បំផុត។
- សម្អាតពីតំបន់ខ្ពស់ទៅតំបន់ទាប និងពីខាងក្រៅទៅផ្នែកខាងក្នុង។
- សម្អាតបន្ទប់ដាច់ដោយឡែកក្រោយគេ។
- ប្រើក្រណាត់ជូតសើម ដើម្បីសម្អាតធូលីដី
- ប្រើប្រព័ន្ធដាក់ធុង ៣ សម្រាប់សម្អាត និងរម្ងាប់មេរោគដូចខាងក្រោម៖
  1. ការលាងសម្អាត (ទឹក និង សាប៊ូ ឬdetergent)
  2. លាងជម្រះ ប្រើតែទឹកប៉ុណ្ណោះ
  3. រម្ងាប់មេរោគដោយប្រើ (Sodium hypochlorite at 0.5% or chlorine 0.5%)
- ទឹកសម្រាប់លាងសម្អាតត្រូវតែជាទឹកស្អាត។

- មានប្រទេសខ្លះដូចជាចិន ថៃ និងវៀតណាម បានប្រប់ប្រាស់សារធាតុបាញ់រម្ងាប់មេរោគនៅក្នុងខ្យល់ឡើយនៅតាមទីធ្លាសាធារណៈ។ ប៉ុន្តែមិនមានភស្តុតាងដែលបង្ហាញថាការប្រើប្រាស់សារធាតុបាញ់រម្ងាប់មេរោគនៅក្នុងខ្យល់ឡើយមានប្រសិទ្ធភាព។ វីរុសដែលបង្កឱ្យមានជំងឺកូវីដ-១៩ ត្រូវបានចម្លងពីមនុស្សទៅមនុស្សតាមរយៈដំណក់តូចៗ ពីផ្លូវដង្ហើម និងការប៉ះពាល់ជាមួយមនុស្សឈឺ ឬផ្ទៃវត្ថុដែលមានមេរោគ។ ការឆ្លងតាមខ្យល់អាចមានលទ្ធភាពក្នុងកាលៈទេសៈជាក់លាក់ដូចជា ទម្រង់ការទាំងឡាយណា ដែលបង្កើតឲ្យមានការសាយភាយភាគតូចៗតាមខ្យល់ (Aerosol generating procedures)។

## ក) ការសម្អាតរថយន្តសង្គ្រោះបន្ទាន់ និងយានយន្តបញ្ជូនអ្នកជំងឺ

- បន្ទាប់ពីបញ្ជូនអ្នកជំងឺរួច សូមទុកទ្វារយានយន្តនៅចំហររយៈពេល១៥ ទៅ ២០នាទី ដើម្បីឲ្យមានការផ្លាស់ប្តូរខ្យល់គ្រប់គ្រាន់មុនពេលត្រឡប់មកវិញ។
- រយៈពេលក្នុងការផ្ទេរអ្នកជំងឺ និងការបំពេញឯកសារផ្សេងៗគួរតែមានពេលគ្រប់គ្រាន់ ដើម្បីបំលាស់ប្តូរខ្យល់ក្នុងរថយន្ត។
- ប្រើការប្រុងប្រយ័ត្នជាស្តង់ដារបស់មន្ទីរពេទ្យ សូមលាងសម្អាតរថយន្តសង្គ្រោះជាមុន បន្ទាប់មកសម្លាប់មេរោគតាមក្រោយ។
- ទ្វារគួរតែបើកនៅពេលលាងសម្អាតយានយន្ត។

## ខ) ការសម្អាតកម្រាលគ្រែ ស្រោមខ្នើយ ឯកសណ្ឋានបុគ្គលិក និងសម្លៀកបំពាក់អ្នកជំងឺ

- កម្រាលកំណាត់ ដែលប្រឡាក់ត្រូវដាក់ក្នុងថង់ ឬធុងមិនលិចធ្លាយ ដែលមានផ្លាកសញ្ញាច្បាស់លាស់។
- គួរប្រើប្រាស់ម៉ាស៊ីនបោកគក់ដោយប្រើទឹកក្តៅនៅសីតុណ្ហភាព ៦០-៩០ អង្សាសេ និងសាប៊ូ។ ការបោកគក់អាចត្រូវបានសម្ងួតដោយយោងទៅតាមនីតិវិធីដែលធ្លាប់ធ្វើ។
- ប្រសិនបើមិនមានម៉ាស៊ីនបោកគក់ ត្រូវត្រាំកម្រាលកំណាត់ ក្នុងទឹកក្តៅ និងសាប៊ូក្នុងធុងធំដោយប្រើកំណាត់ឈើ ដើម្បីកូរដោយប្រុងប្រយ័ត្ន ដើម្បីចៀសវាងកុំអោយខ្ទាត។ បន្ទាប់មកចាក់ទឹកចេញពីធុង ហើយត្រាំកម្រាលក្រណាត់ក្នុងក្លរីន ០.០៥% យ៉ាងតិច ៣០នាទី។ ចុងបញ្ចប់ការបោកគក់ត្រូវបានលាងជម្រះដោយទឹកស្អាតហើយហាលឱ្យស្ងួតដោយពន្លឺព្រះអាទិត្យ។
- ប្រសិនបើលាមក ឬទឹកនោមអ្នកជំងឺនៅលើផ្ទៃ (ដូចជាកម្រាលកំណាត់ ឬកម្រាលឥដ្ឋ) គួរប្រើក្រដាសជូតដើម្បីជូតប្រមូលលាមក ឬទឹកនោមទៅចោលភ្លាមៗនៅក្នុងបង្គន់។ ប្រសិនបើកន្សែងនោះសម្រាប់ប្រើតែម្តងយើងត្រូវចាត់ទុកវាជាកាកសំណល់ឆ្លងរោគ។ ប្រសិនបើកន្សែងអាចប្រើឡើងវិញបាន យើងត្រូវចាត់ទុកវាជាកម្រាលក្រណាត់ដែលប្រឡាក់។ បន្ទាប់មកត្រូវជូតសម្អាត និងសម្លាប់មេរោគ (ជាមួយក្លរីន ០.៥%) កន្លែងដែលប្រឡាក់។

## ១០- ការគ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ

- រាល់កាកសំណល់វេជ្ជសាស្ត្រ ដែលមានក្នុងកំឡុងពេលនៃការថែទាំអ្នកជំងឺកូវីដ-១៩ ត្រូវតែអនុវត្តដូចគ្នាតាមនីតិវិធីប្រតិបត្តិស្តង់ដារនៃការចោលសំណល់ឆ្លងរោគនៃមេរោគរបេង និងមេរោគអេដស៍ (ឧទាហរណ៍ ប្រមូលដាក់ក្នុងធុង ឬថង់សម្រាប់សំណល់ឆ្លងរោគ ធ្វើប្រព្រឹត្តកម្មសម្លាប់មេរោគ ឬដុតសំណល់ឆ្លងរោគរាល់ថ្ងៃនៅក្នុងឡបើអាចធ្វើទៅបាន បើមិនដូច្នេះទេត្រូវរម្ងាប់មេរោគដោយប្រើអូតូក្លាវ មុនពេលបញ្ជូនទៅមន្ទីរពេទ្យដែលមានឡដុតសម្រាម) ។
- ប្រសិនបើកាកសំណល់ត្រូវយកចេញពីមូលដ្ឋានសុខាភិបាល វាជាការសំខាន់ណាស់ដែលត្រូវយល់ដឹងថាតើកាកសំណល់នោះនឹងត្រូវគេធ្វើប្រព្រឹត្តកម្មសម្លាប់មេរោគ និងកំទេចចោលនៅទីកន្លែងណា និង យ៉ាងដូចម្តេច។

----------------------------------------

# ឧបសម្ព័ន្ធ ១. ឧបករណ៍ការពារខ្លួនសម្រាប់ជំងឺកូវីដ-១៩

## យោងទៅតាមការទីកន្លែង បុគ្គលិក និងប្រភេទសកម្មភាព

| **ទីកន្លែង** ( Setting ) | **ក្រុមគោលដៅ** ( Target audience ) | **សកម្មភាព** ( Activity ) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវប៉ំពង់(Gown) | អាវអៀមធន់ទ្រាំទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| កន្លែងទទួលជំងឺដំបូង (Triage) | បុគ្គលិកថែទាំសុខភាព | ការត្រួតពិនិត្យជំងឺដំបូងដែល មិនទាក់ទងនឹងការថែទាំផ្ទាល់ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ តែត្រូវរក្សាគំលាតយ៉ាងហោច១ម៉ែត្រ។ បើមិនអាចរក្សាគម្លាតបាន សូមពាក់ម៉ាស់វះកាត់ និងវែនតាការពារ ឬរបាំងការពារ។ | | | | | | |
| | អ្នកជំងឺដែលមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | | X | | | | | |
| | អ្នកជំងឺដែលមិនមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| បន្ទប់ពិគ្រោះជំងឺក្រៅ | បុគ្គលិកថែទាំសុខភាព | ពិនិត្យរាងកាយអ្នកជំងឺដែល មានរោគសញ្ញាផ្លូវដង្ហើម | X | X | | X | X | | |
| | | ពិនិត្យរាងកាយអ្នកជំងឺដែល មិនមានរោគសញ្ញាផ្លូវដង្ហើម | ការប្រុងប្រយ័ត្នជាស្តង់ដា និងវាយតម្លៃពីហានិភ័យ | | | | | | |
| | អ្នកជំងឺដែលមានរោគសញ្ញាផ្លូវដង្ហើម | រាល់អ្នកជំងឺ | | X | | | | | |
| | អ្នកជំងឺដែលមិនមានរោគសញ្ញាផ្លូវដង្ហើម | | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| បន្ទប់អ្នកជំងឺ | បុគ្គលិកថែទាំសុខភាព | ការថែទាំអ្នកជំងឺកូវីដ-១៩ផ្ទាល់ | X | X | | X | X | | |
| | | សកម្មភាពដែលបង្កើតឲ្យមានភាគល្អិតតូចៗតាមខ្យល់ (Aerosol generating procedures[1])** | X | | X | X | X | X | |
| មន្ទីរពិសោធន៍ | បុគ្គលិកថែទាំសុខភាព | ការយកសំណាកចេញពីផ្លូវ ដង្ហើម | X | X | | X | X | | |

| **ទីកន្លែង** ( Setting ) | **ក្រុមគោលដៅ** ( Target audience ) | **សកម្មភាព** ( Activity ) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវបំពង់(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| | | ការយកសំណាកចេញពីផ្លូវដង្ហើមដែលអាចបង្កើតឲ្យមានការសាយភាយភាគល្អិតតូចៗតាមខ្យល់ | X | | X | X | X | X | |
| កន្លែងរដ្ឋបាល | គ្រប់បុគ្គលិកទាំងអស់ | ការងាររដ្ឋបាលដែលមិនទាក់ ទងនឹងការប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ | | | | | | |
| គ្រប់ទីកន្លែង | បុគ្គលិកអនាម័យ | ចូលក្នុងបន្ទប់អ្នកជំងឺសង្ស័យ និងបញ្ជាក់ជំងឺកូវីដ-១៩ | X* | X | | X | X | | X |
| **មន្ទីរពិសោធន៍** | | | | | | | | | |
| មន្ទីរពិសោធន៍ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍ | តេស្ត Molecular ការកាន់និងរៀបចំសំណាកសម្រាប់ធ្វើ RT-PCR-testing | អនុវត្តទៅតាមសេចក្តីណែនាំសុវត្ថិភាពរបស់អង្គការសុខភាពពិភពលោកស្តីពីជំងឺកូវីដ-១៩៖ ស្រោមដៃ អាវបំពង់ អាវអៀមដៃវែងដែលគ្របដៃជិត គម្របក្បាល (Coverall), គម្របស្បែកជើង និងវ៉ែនតាការពារភ្នែក ឬរបាំងការពារមុខ។ ហានិភ័យអាចប្រាប់ឲ្យដឹងពីការប្រើប្រាស់ម៉ាស់សម្រាប់ការពារផ្លូវដង្ហើម (e.g. N95 mask). | | | | | | |
| **មធ្យោបាយធ្វើដំណើរ** | | | | | | | | | |
| **រថយន្តសង្គ្រោះបន្ទាន់ ឬរថយន្តដឹកអ្នកជំងឺ** | បុគ្គលិកថែទាំសុខភាព | ដឹកអ្នកជំងឺសង្ស័យជំងឺកូវីដ-១៩ ទៅមូលដ្ឋានសុខាភិបាល មួយទៀត | X | X | | X | X | | |
| | អ្នកបើកបរ | ពេលបើកបរ ហើយនិងកន្លែងអ្នកបើកបរខណ្ឌដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួនឡើយ តែរក្សាគំលាតយ៉ាងហោច១ម៉ែត្រ | | | | | | |

| ទីកន្លែង ( Setting ) | ក្រុមគោលដៅ ( Target audience ) | សកម្មភាព ( Activity ) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវបំពង់(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| | | ពេលបើកបរ ហើយ និងកន្លែងអ្នកបើកបរ មិនខណ្ឌដាច់ពីអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | | X | | | | | |
| | | នៅពេលជួយលើកដាក់អ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | X | X | | X | X | | |
| | អ្នកជំងឺ | ដឹកទៅមូលដ្ឋានសុខាភិបាលមួយផ្សេងទៀត | | X | | | | | |
| | បុគ្គលិកអនាម័យ | សម្អាតបន្ទាប់/រវាងដឹកអ្នកជំងឺសង្ស័យកូវីដ-១៩ | X* | X | | X | X | | X |
| **នៅសហគមន៍ និងផ្ទះ** | | | | | | | | | |
| សហគមន៍ | **ក្រុមឆ្លើយតបបន្ទាន់** | សម្រាប់ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកជំងឺសង្ស័យឬអ្នកជំងឺកូវីដ-១៩ | ត្រូវតែពាក់ម៉ាស់វះកាត់<br>ត្រូវអនុវត្តរក្សាគំលាតពីគ្នាយ៉ាងតិច ១ ម៉ែត្រ | | | | | | |
| | | សម្រាប់ការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកជំងឺដែល មិនមានរោគសញ្ញាបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ-១៩ | មិនតម្រូវឲ្យពាក់ឧបករណ៍ការពារខ្លួន PPE ឡើយ<br>ត្រូវរក្សាគំលាតយ៉ាងហោច១ម៉ែត្រ | | | | | | |
| | | ការប្រមូលសំណាកពីផ្លូវដង្ហើម | X | X | | X | X | | |
| | **បុគ្គលិកថែទាំសុខភាព** | ផ្តល់ការថែទាំផ្ទាល់ចំពោះអ្នកជំងឺសង្ស័យ ឬអ្នកជំងឺកូវីដ-១៩ | X | X | | X | X | | |

| ទីកន្លែង ( Setting ) | ក្រុមគោលដៅ ( Target audience ) | សកម្មភាព ( Activity ) | ស្រោមដៃ (Gloves) | ម៉ាស់វះកាត់ | ម៉ាស់ N95 | វ៉ែនតា ឬរបាំងការពារមុខ | អាវបំពង់(Gown) | អាវអៀមមិនជ្រាបទឹក | ស្បែកជើងកវែង ឬបិទជិត (Boots or closed shoes) |
|---|---|---|---|---|---|---|---|---|---|
| ផ្ទះ | អ្នកជំងឺដែលមានរោគ សញ្ញផ្លូវដង្ហើម | សកម្មភាពផ្សេងៗ | | X | | | | | |
| | អ្នកមើលថែអ្នកជំងឺ | ចូលក្នុងបន្ទប់អ្នកជំងឺសង្ស័យនិងជំងឺកូវីដ-១៩ តែមិនធ្វើការថែទាំផ្ទាល់ទេ | | X | | | | | |
| | | ផ្តល់ការថែទាំផ្ទាល់ដល់អ្នកជំងឺសង្ស័យ និង ជំងឺកូវីដ-១៩ ឬពេលយកលាមកចាក់ចោល ឬទឹកនោមឬសំរាម | X | X | | | | (ប្រសិនបើមានហានិភ័យនៃការខ្ទាតសរីរៈរាវ) | |

*ស្រោមដៃក្រាស់

**ឧទាហរណ៍នៃទម្រង់ការទាំងឡាយណាដែលបង្កើតឲ្យមានសាយភាយភាគល្អិតតូចៗតាមខ្យល់ ដូចជាការស៊កបំពង់ខ្យល់ដើម្បីសប់ដង្ហើម (Tracheal intubation) ការសប់ដង្ហើមដោយដៃ (non-invasive ventilation) ការចោះបំពង់ខ្យល់ (tracheotomy) ការសង្កត់សង្គ្រោះផ្លូវដង្ហើមបេះដូង (cardiopulmonary resuscitation) ការស៊កឆ្លុះទងសួត (bronchoscopy)-

កំណត់សម្គាល់បន្ថែម៖

- តារាងទី១ តំណាងឲ្យស្តង់ដារអប្បបរមាសម្រាប់ឧបករណ៍ការពារខ្លួនPPE ដោយពឹងផ្អែកលើអនុសាសន៍របស់អង្គការសុខភាពពិភពលោក។ ការវាយតម្លៃពីហានិភ័យ ត្រូវតែធ្វើមុនពេលចាប់ផ្តើមនិតិវិធីវេជ្ជសាស្ត្រ ថែទាំ មន្ទីរពិសោធន៍ ឬនិតិវិធីផ្សេងៗទៀត ដើម្បីឲ្យប្រាកដថាបុគ្គលិកទាំងអស់មានសុវត្ថភាព និងកាត់បន្ថយការប្រើប្រាស់ដែលមិនសមស្រប។
- គម្របក្បាល អាវបំពង់គ្របទាំងមូល និងស្បែកជើងជ័រកវែង មិនចាំបាច់ទេនៅពេលដែលធ្វើការថែទាំផ្ទាល់ជាមួយអ្នកជំងឺសង្ស័យកូវីដ-១៩ ឬអ្នកជំងឺកូវីដ-១៩។

# ឧបសម្ព័ន្ធ២. ការជ្រើសរើស និង បែងចែក ឬ ចរន្តអ្នកជំងឺ




Version 1.0 (6 May 2020)

*យោងតាមនិយមន័យករណីសង្ស័យ Covid-19 របស់ក្រសួងសុខាភិបាលចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០២០

----------------------------